# ផ្នែកទី១៖ ការដ្ឋានសំណង់ទូទៅ

## ចំណុចសំខាន់សម្រាប់សុវត្ថិភាពនិងសុខភាព

### (1) ការបណ្តុះបណ្តាលនៅពេលជ្រើសរើស, ការបណ្តុះបណ្តាលបញ្ជូនចេញ និងការបណ្តុះបណ្តាលបុគ្គលិកថ្មី

ច្បាប់សុវត្ថិភាពការងារនិងសុខភាពចែងថានិយោជកត្រូវតែផ្តល់ការអប់រំបណ្តុះបណ្តាលពីសុខភាពនិងសុវត្ថិភាពផ្សេងៗ។ អ្នកអាចទទួលការបណ្តុះបណ្តាលតាមតម្រូវការ។

**1. ការបណ្តុះបណ្តាលនៅពេលបំពេញការងារ៖**

នៅពេលជួលបុគ្គលិកណាម្នាក់ ចូរផ្តល់បណ្តុះបណ្តាលអំពីសុវត្ថិភាពនិងសុខភាពទាក់ទងនឹងការងារដែលត្រូវធ្វើ។

**2. ការបណ្តុះបណ្តាលបុគ្គលិកចូលថ្មី៖**

ការបណ្តុះបណ្តាលបុគ្គលិកចូលថ្មីគឺផ្តោតលើស្ថានភាពការដ្ឋាន, ផែនការការងារ, ទីតាំងគ្រោះថ្នាក់, និងច្បាប់ទាំងឡាយប្រចាំការដ្ឋាន។ (បន្ទាប់ពីពិនិត្យលើបទពិសោធន៍ការងារ, ស្ថានភាពសុខភាព, ។ល។ របស់បុគ្គលិកចូលថ្មី, ព័ត៌មាននេះត្រូវប្រើជាឯកសារយោងសម្រាប់ការរៀបចំឲ្យបានសមស្រប។)

* ក្រៅពីចំណុចខាងលើ និយោជកត្រូវផ្តល់ការបណ្តុះបណ្តាលពីសុវត្ថិភាពនិងការអប់រំបណ្តុះបណ្តាលបញ្ជូនទៅកន្លែងការងារដទៃទៀតមុននឹងបញ្ជូនទៅកាន់ការដ្ឋានសំណង់។ លើសពីនេះទៀត ដើម្បីបំពេញការងារដែលគ្រោះថ្នាក់ដូចជាការប្រើប្រាស់រថយន្តស្ទូច ចាំបាច់ត្រូវមានបណ្ណអនុញ្ញាតតាមច្បាប់កំណត់ និងចូលរួមវគ្គបណ្តុះបណ្តាលជំនាញនិងការបណ្តុះបណ្តាលពិសេស។



## (2) ឧទាហរណ៍អំពីគ្រោះថ្នាក់ការងារនៅក្នុងការដ្ឋានសំណង់

### ការធ្លាក់ដងសន្ទូច



### វត្ថុធ្លាក់ឬខ្ទាតលើនៅអំឡុងពេលបំពេញការងារវាយកម្ទេច



### ការបាក់ដី



### ការធ្លាក់ពីលើជណ្ដើរ



### គ្រឿងចក្រកាយដីកិនលើ



### ធ្លាក់នៅអំឡុងពេលដំឡើងរន្ទា



### ធ្លាក់ពីលើជណ្ដើរ



### គាបជាប់នឹងបន្ទុកស្ទូច



## (3) សម្លៀកបំពាក់សមស្រប

### ជំហានសុវត្ថិភាពបឋមគឺស្លៀកពាក់ឲ្យបានត្រឹមត្រូវ!




* តាមច្បាប់កំណត់ ប្រព័ន្ធបង្ការការធ្លាក់គួរតែជាប្រភេទចង្វាយខ្សែពេញលេញ ប៉ុន្តែប្រសិនបើធ្វើការនៅកម្ពស់ 5 ម៉ែត្រឬទាបជាងនេះ គេអាចប្រើ "ប្រភេទខ្សែក្រវាត់ចង្កេះ"។

## [គ្រឿងបរិក្ខារការពារសមស្រប]

## ច្បាប់បានកំណត់ថានៅពេលបំពេញការងារ អ្នកត្រូវតែពាក់គ្រឿងបរិក្ខាការពារចាំបាច់ និងថាត្រូវតែពាក់គ្រឿងបរិក្ខាការពារសុវត្ថិភាពឲ្យបានត្រឹមត្រូវដើម្បីការពារខ្លួនអ្នក។



# (4) ក្រមសុវត្ថិភាពនៅក្នុងការដ្ឋានសំណង់

## ហាមធ្វើសកម្មភាពទាំងនេះជាដាច់ខាត!




## បញ្ហាដែលត្រូវអនុវត្ត

- ចូរប្រាកដថាបានប្រើផ្លូវសុវត្ថិភាព។
- ហាមចូលទៅក្នុងដែនប្រតិបត្តិការនៃគ្រឿងចក្រធន់ធ្ងន់។
- ហាមចូលទៅកាន់ទីកន្លែងស្តុកសម្ភារដោយខ្វះការប្រុងប្រយ័ត្ន។
- ប្រើឧបករណ៍យោងដែលបានកំណត់នៅពេលទៅកាន់កន្លែងការងារនៅជាន់ទីពីរ ឬជាន់ខ្ពស់ជាងនេះ។
- កន្លែងសម្រាកត្រូវតែជាទីតាំងនិងតំបន់ម៉ោងដែលបានកំណត់។
- ត្រូវតែអនុវត្តតាមខ្លឹមសារការងារនិងការណែនាំរបស់មេការ ឬអ្នកគ្រប់គ្រងឲ្យបានហ្មត់ចត់។

## (5) សកម្មភាព STCC (ការរៀបចំតាមប្រភេទ-សណ្ដាប់ធ្នាប់- សម្អាត-អនាម័យ)

**STCC**: ការរៀបចំតាមប្រភេទ, សណ្ដាប់ធ្នាប់, សម្អាត, អនាម័យ

មូលដ្ឋានគ្រឹះនៃសុវត្ថិភាពគឺសណ្ដាប់ធ្នាប់។ នៅក្នុងការដ្ឋានសំណង់តែងតែមានគ្រោះថ្នាក់ជំពប់ជើងនិងដួល
ប៉ុន្តែប្រសិនបើរបស់របរមានសណ្ដាប់ធ្នាប់និងទុកដាក់មានរបៀបរៀបរយ ឬមិនមានគ្រឿងជំពប់ នោះគេអាចកាត់បន្ថយគ្រោះថ្នាក់ជំពប់ដួលបាន។



## [នៅពេលបញ្ចប់ការងារ]



- ចូររៀបចំទុកដាក់បន្ទាប់ពីបំពេញការងាររួច។
- ចូរស្អាតទីកន្លែងឡើងវិញ។

# ( 6 ) វដ្តសំណង់មានសុវត្ថិភាព

វដ្តសំណង់មានសុវត្ថិភាពទាក់ទងនឹងសកម្មភាពសុវត្ថិភាពផ្សេងទៅក្នុងការងារប្រចាំថ្ងៃនៅក្នុងការដ្ឋានការងារ។

## [វដ្តសំណង់មានសុវត្ថិភាពប្រចាំថ្ងៃ]



## (7) សកម្មភាពព្យាករណ៍ហានិភ័យនៅកន្លែងការងារ



ដោយចុះទៅមើលកន្លែងត្រូវបំពេញការងារ, សមាជិកទាំងអស់ពិភាក្សា “គ្រោះថ្នាក់នៅកន្លែងការងារនៅថ្ងៃនោះ និងថាតើត្រូវយកចិត្តទុកដាក់ដូចម្តេចនៅពេលបំពេញការងារនៅទីនេះ។”។

1. គិតគូរពីគ្រោះថ្នាក់ដែលអាចកើតឡើង ប្រសិនបើអ្នកបំពេញការងារតាមការណែនាំនៅទីនេះ។( ឧទាហរណ៍ )
    - នៅត្រង់កន្លែងការងារ តើមានប្រឡោះដែលងាយបណ្តាលឲ្យធ្លាក់ដែរឬទេ ?
    - តើមានកន្លែងណាមួយដែលអាចបណ្តាលឲ្យប៉ះនឹងគ្រឿងចក្រដែរឬទេ ?
    - តើគេបានណែនាំអ្នកអំពីការងារផ្សេងដែរឬទេ ?
2. ប្រាប់អ្នកទទួលខុសត្រូវពីអ្វីមួយដែលអ្នកមាននៅក្នុងចិត្ត។
3. ប្រសិនបើអ្នកមិនទាន់យល់ការណែនាំពីអ្នកទទួលខុសត្រូវការងារទេ ចូរសួរបញ្ជាក់វារហូតទាល់តែអ្នកយល់។

# (៨) ឧទាហរណ៍អំពីសញ្ញាសុវត្ថិភាព



ហាមចូល



ហាមជក់បារី



ហាមបង្កាត់ភ្លើង



ហាមចត


ការហាមឃាត់ទូទៅ



ប្រយ័ត្នប៉ះក្បាល



ប្រយ័ត្នប៉ះជើង



ប្រយ័ត្នស្ទុះធ្លាក់



ប្រយ័ត្នឆក់



ប្រយ័ត្នធ្លាក់



ប្រយ័ត្នធ្លាក់ផ្លូវ



ប្រយ័ត្នចំពោះកង្វះអុកស៊ីហ្សែន



ប្រយ័ត្នសារធាតុរលាយសរីរាង្គ


ការព្រមានទូទៅ



ចូរប្រើចង្កាយខ្សែបង្ការការធ្លាក់



ចូរពាក់មួកសុវត្ថិភាព ឲ្យបានត្រឹមត្រូវ


សកម្មភាពតម្រូវជាទូទៅ



ចូររៀបចំសណ្តាប់ធ្នាប់និងសម្អាត



សមត្ថភាពផ្ទុកអតិបរមា



តំបន់ជក់បារី



គ្រែស្នែង



ច្រកសុវត្ថិភាព



ជណ្តើរ



កន្លែងសម្រាក



បំពង់ពន្លត់អគ្គិភ័យ



កន្លែងចុចប្រកាសអាសន្ន



AED

នៅក្នុងការដ្ឋានសំណង់ គេបិទស្លាកសញ្ញានានានៅត្រង់ចំណុចគ្រោះថ្នាក់តាមច្បាប់ដែលកំណត់ដោយសមាជិកទាំងអស់។ ចូរស្វែងយល់ពីអត្ថន័យនៃសញ្ញា និងអនុវត្តតាម។

出典：建設業労働災害防止協会
Japan Construction Occupational Safety and Helth Association